**ឧបសម្ព័ន្ធ១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ....០០៣............សហវ

# សេចក្ដីណែនាំ

# ស្ដីពី

# ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ ក៏ដូចជា បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា ឱ្យបានជ្រាបថា អនុវត្តស្របតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំនូវប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មី ដើម្បីសម្រួលដល់ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ធានាបាននូវតម្លាភាព ភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមជម្រាបជូនថា គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ក៏ដូចជា បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា ត្រូវដាក់លិខិតប្រកាសសម្រាប់រយៈពេលជាប់ពន្ធខែមិថុនា ឆ្នាំ២០២០ តរៀងទៅ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដូចខាងក្រោម÷

## I. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ

អ្នកជាប់ពន្ធមធ្យមនិងធំទាំងអស់ត្រូវដាក់លិខិតប្រកាសដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង ដោយរួចផុតពីពន្ធបន្ថែម ១០% ពីការយឺតយ៉ាវក្នុងការដាក់លិខិតប្រកាស។ ដោយឡែក ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធមធ្យមអាចបំពេញលិខិតប្រកាសដោយដៃនិងដាក់លិខិតប្រកាសនៅរដ្ឋបាលសារពើពន្ធ ប៉ុន្តែត្រូវបន្តការប្រើប្រាស់ការស្នើសុំបង្វិលសងឬឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ (Online-VAT Refund and Online-VAT Credit) ស្របតាមសេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង។ អគ្គនាយកដ្ឋានពន្ធដារនឹងចេញសេចក្តីណែនាំបន្ថែមស្តីពីអំពីការកំណត់រយៈពេលសមស្របក្នុងការបញ្ចប់ការពន្យារការអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing)។ ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) អ្នកជាប់ពន្ធមធ្យមនិងធំត្រូវអនុវត្តដូចខាងក្រោម÷

**១. ការប្រើប្រាស់ប្រព័ន្ធ**

ក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ អ្នកប្រើប្រាស់ដែលពុំទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធដោយចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ដើម្បីចុះបញ្ជីប្រើប្រាស់ប្រព័ន្ធ ដោយត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷

- លេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT TIN)
- លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានផ្តល់ជូនលោក-លោកស្រី
- លេខទូរស័ព្ទដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គ-នាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

អ្នកប្រើប្រាស់នឹងទទួលបាន ឈ្មោះសម្រាប់ប្រើប្រាស់ (User Name) និង លេខកូដសម្ងាត់ (Password) ដែលត្រូវបានផ្ញើទៅកាន់អ៊ីម៉ែល (E-mail) និងលេខទូរស័ព្ទរបស់ម្ចាស់សហគ្រាសឬអ្នកប្រើប្រាស់ នៅពេលព័ត៌មានដែលតម្រូវខាងលើត្រូវបានវាយបញ្ចូលពេញលេញ។

**២. នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធ**

ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) អ្នកប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីលម្អិត ដូចខាងក្រោម÷

- ចូលទៅគេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ដោយប្រើប្រាស់គណនីប្រើប្រាស់ប្រព័ន្ធ និងជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ
- បញ្ចូលទិន្នន័យបញ្ជីនិងវិក្កយបត្រទិញ-លក់
- បញ្ចូលទិន្នន័យពាក់ព័ន្ធនឹងការប្រកាសពន្ធកាត់ទុក
- បញ្ចូលទិន្នន័យពាក់ព័ន្ធនឹងការប្រកាសពន្ធលើប្រាក់បៀវត្ស និងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម
- ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) ក្នុងករណីនេះអ្នកជាប់ពន្ធពុំចាំបាច់យកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ។ ដោយឡែក ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកជាប់ពន្ធត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធមកកាន់រដ្ឋបាលសារពើពន្ធដែលគ្រប់គ្រងសហគ្រាសនោះ។

## II. សម្រាប់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចអាចដាក់លិខិតប្រកាសដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញសម្រាប់អ្នកជាប់ពន្ធតូច (GDT Taxpayer App) យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង ដោយរួចផុតពីពន្ធបន្ថែម១០% ពីការយឺតយ៉ាវក្នុងការដាក់លិខិតប្រកាស។ ចំពោះ ការបំពេញលិខិតប្រកាសដោយដៃ អ្នកជាប់ពន្ធតូចត្រូវដាក់លិខិតប្រកាសនៅរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង។ ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញសម្រាប់អ្នកជាប់ពន្ធតូច (GDT Taxpayer App) អ្នកជាប់ពន្ធតូចត្រូវអនុវត្តដូចខាងក្រោម÷

## ១. ការប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ អ្នកប្រើប្រាស់ដែលពុំទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធដោយចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ឬទាញយកពី App Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ iOS) ឬទាញយកពី Play Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ Android) ដោយត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷

- លេខអត្តសញ្ញាណកម្មសារពើពន្ធ (BIN)
- លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានផ្តល់ជូនលោក-លោកស្រី
- លេខទូរស័ព្ទដៃដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

អ្នកប្រើប្រាស់នឹងទទួលបាន ឈ្មោះសម្រាប់ប្រើប្រាស់ (User Name) និង លេខកូដសម្ងាត់ (Password) ដែលត្រូវបានផ្ញើទៅកាន់អ៊ីម៉ែល (E-mail) និងលេខទូរស័ព្ទរបស់ម្ចាស់សហគ្រាសឬអ្នកប្រើប្រាស់ នៅពេលព័ត៌មានដែលតម្រូវខាងលើត្រូវបានវាយបញ្ចូលពេញលេញ។

## ២. នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញសម្រាប់អ្នកជាប់ពន្ធតូច (GDT Taxpayer App) អ្នកប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីលម្អិត ដូចខាងក្រោម÷

- បញ្ចូលទិន្នន័យទិញ-លក់របស់សហគ្រាស
- ពិនិត្យប្រាក់ពន្ធដែលគណនាដោយស្វ័យប្រវត្តិ
- ត្រូវបំពេញបន្ថែមប្រាក់ពន្ធ-អាករផ្សេងៗប្រសិនបើមាន
- ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) ក្នុងករណីនេះអ្នកជាប់ពន្ធពុំចាំបាច់យកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ។ ដោយឡែក ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកជាប់ពន្ធត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធមកកាន់រដ្ឋបាលសារពើពន្ធដែលគ្រប់គ្រងសហគ្រាសនោះ។

## III. ទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ

ចំពោះករណីបំពេញនិងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែ អ្នកជាប់ពន្ធត្រូវអនុវត្តដូចខាងក្រោម÷

- បំពេញនិងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែស្របតាមទម្រង់លិខិតប្រកាសប្រចាំខែថ្មី ដូចមានភ្ជាប់ជាមួយសេចក្តីណែនាំនេះ ឬអាចទាញយកពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh
- ប្រកាសនិងបង់ប្រាក់ពន្ធគ្រប់ប្រភេទសម្រាប់ខែនីមួយៗយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់

- លិខិតប្រកាសបង់ពន្ធប្រចាំខែថ្មីត្រូវរៀបចំសម្រាប់គ្រប់ប្រភេទពន្ធដែលត្រូវប្រកាសប្រចាំខែ ហើយចំពោះសហគ្រាសដែលមានសាខា លិខិតប្រកាសពន្ធប្រចាំខែត្រូវមានលិខិតប្រកាសពន្ធសម្រាប់ទីស្នាក់ការកណ្តាល សាខារបស់សហគ្រាស និងលិខិតប្រកាសពន្ធសរុបប្រចាំខែ
- អ្នកជាប់ពន្ធត្រូវបន្តការប្រើប្រាស់ការស្នើសុំបង្វិលសងឬឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ (Online-VAT Refund and Online-VAT Credit) ស្របតាមសេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

*ដើម្បីធ្វើការស្វែងយល់បន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មី អ្នកប្រើប្រាស់អាចពិនិត្យមើលលម្អិតក្នុងសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅលើគេហទំព័រ www.tax.gov.kh ឬចូលទស្សនាវីដេអូណែនាំ (Video Tutorial) ឬអាចទូរស័ព្ទមក Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។*

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ ក៏ដូចជា បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ ដើម្បីធ្វើការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែឱ្យបានត្រឹមត្រូវនិងទទួលបានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ[illegible]ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ខែ[illegible]ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានពន្ធដារ
  "ដើម្បីមុខការ"
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីចូលរួមផ្សព្វផ្សាយ"
- ស្ថានបេសកកម្មរបស់ប្រទេសនានាតាំងនៅព្រះរាជាណាចក្រកម្ពុជា
- ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា
- អង្គការអន្តរជាតិនានាតាំងនៅព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៧៧០៥.....អពដ

L20191102001 | TD3110

ថ្ងៃចន្ទ ១៥កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២០

## សេចក្ដីណែនាំ
## ស្ដីពី
## នីតិវិធីនៃការស្កេន និងបញ្ជូនលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ និងលិខិតប្រកាសពន្ធប្រចាំខែកុម្ភៈ ដល់ ខែមិថុនា តាមសេវាកម្មអនឡាញ របស់អគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនលោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងអ្នកជាប់ពន្ធទាំងឡាយឱ្យបានជ្រាបថា ក្នុងគោលបំណងចូលរួមកាត់បន្ថយនិងទប់ស្កាត់ហានិភ័យនានានៃការរីករាលដាលនៃជំងឺកូវីដ ១៩ (Covid-19) ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំយន្តការស្កេន និងបញ្ជូនលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ និងលិខិតប្រកាសពន្ធប្រចាំខែកុម្ភៈ ដល់ ខែមិថុនា តាមសេវាកម្មអនឡាញ របស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជាការសម្រួលដល់អ្នកជាប់ពន្ធក្នុងការដាក់លិខិតប្រកាសពន្ធនេះ។

អ្នកជាប់ពន្ធទាំងឡាយណាដែលមានបំណងដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ និងលិខិតប្រកាសពន្ធប្រចាំខែកុម្ភៈ ដល់ ខែមិថុនា អាចធ្វើការបញ្ជូនលិខិតប្រកាសពន្ធ ដោយគ្រាន់តែស្កេនលិខិតប្រកាសពន្ធ និងឯកសារពាក់ព័ន្ធផ្សេងៗ ហើយបញ្ចូល (Upload) ឯកសារដែលបានស្កេនមកកាន់អគ្គនាយកដ្ឋានពន្ធដារតែម្តង។ ដើម្បីបញ្ចូល (Upload) ឯកសារទាំងនេះ អ្នកជាប់ពន្ធត្រូវចូលប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service) ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

**១. ការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ**

ក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service) អ្នកប្រើប្រាស់ដែលពុំទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធនេះដោយចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ដើម្បីចុះឈ្មោះប្រើប្រាស់ ដោយត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷

- អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ប្រព័ន្ធ
- លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង
- សារអេឡិចត្រូនិក (E-mail) សម្រាប់ទំនាក់ទំនង។

អ្នកប្រើប្រាស់នឹងទទួលបាន ឈ្មោះសម្រាប់ប្រើប្រាស់ (User Name) និង លេខកូដសម្ងាត់ (Password) ដែលត្រូវបានផ្ញើទៅកាន់អ៊ីម៉ែល (E-mail) និងលេខទូរស័ព្ទរបស់ម្ចាស់សហគ្រាសឬអ្នកប្រើប្រាស់ នៅពេលព័ត៌មានដែលតម្រូវខាងលើត្រូវបានវាយបញ្ចូលពេញលេញ។

**២. នីតិវិធីលម្អិតក្នុងការស្កេននិងបញ្ជូនលិខិតប្រកាសពន្ធប្រចាំឆ្នាំ២០១៩ និងលិខិតប្រកាសពន្ធប្រចាំខែ**

**ជំហានទី១÷** ១. សម្រាប់ការដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ២០១៩÷ ត្រូវបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩

២. សម្រាប់ការដាក់លិខិតប្រកាសពន្ធប្រចាំខែ÷ ត្រូវបំពេញលិខិតប្រកាសពន្ធប្រចាំខែ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការប្រើប្រាស់ឥណទានអាករលើតម្លៃបន្ថែម តាមរយៈការប្រើប្រាស់ការស្នើសុំបង្វិលសងឬឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករ

L20191102001 | TD3110

លើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ (Online-VAT Refund and VAT Credit) ស្របតាមសេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ជំហានទី២÷** អញ្ជើញទៅបង់ប្រាក់ពន្ធដែលបានប្រកាសគ្រប់ចំនួននៅធនាគារជាដៃគូដែលមានចុះអនុស្សរណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការបង់ប្រាក់ពន្ធតាមអនឡាញ (E-Payment) របស់អគ្គនាយកដ្ឋានពន្ធដារតែម្តង។

**ជំហានទី៣÷** ចូលទៅគេហទំព័រដែលមានអាសយដ្ឋាន÷ www.tax.gov.kh រួចវាយបញ្ចូលឈ្មោះសម្រាប់ប្រើប្រាស់ (Username) និងលេខកូដសម្ងាត់ (Password) ដែលទទួលបាន។

**ជំហានទី៤÷** បន្ទាប់មកត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷

- លេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT TIN)
- លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង
- សារអេឡិចត្រូនិក (E-mail) សម្រាប់ទំនាក់ទំនង។

**ជំហានទី៥÷** ស្កេនឯកសារទម្រង់លិខិតប្រកាសដែលបានបំពេញ បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ និងឯកសារពាក់ព័ន្ធផ្សេងៗ ហើយបញ្ចូល (Upload) ចូលក្នុងប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារជាការស្រេច។

**ជំហានទី៦÷** បន្ទាប់មក អ្នកជាប់ពន្ធនឹងទទួលសារអេឡិចត្រូនិកហើយត្រូវបោះពុម្ព "**លិខិតបញ្ជាក់ថាបានទទួលលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ ឬលិខិតប្រកាសពន្ធប្រចាំខែ**" ពីប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

- បន្ទាប់ពីទទួលបានសារអេឡិចត្រូនិកពីអគ្គនាយកដ្ឋានពន្ធដាររួចហើយ អ្នកជាប់ពន្ធត្រូវបានសន្មតថាបានដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំរួចរាល់
- អ្នកជាប់ពន្ធត្រូវរក្សាទុកឱ្យបានត្រឹមត្រូវនូវច្បាប់ដើមនៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ ឬលិខិតប្រកាសពន្ធប្រចាំខែ របស់ខ្លួន និងប្រគល់មកអគ្គនាយកដ្ឋានពន្ធដារ ឬអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ (នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត-ខណ្ឌ) តាមក្រោយដែលអាចធ្វើទៅបានក្នុងរយៈពេលមិនលើសពី ៣ ខែ។

*ដើម្បីធ្វើការស្វែងយល់បន្ថែមអំពីនីតិវិធីខាងលើ អ្នកប្រើប្រាស់អាចទូរស័ព្ទមក Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។*

សេចក្តីណែនាំនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់ខែមិថុនា ឆ្នាំ២០២០ ហើយចាប់ពីរយៈពេលជាប់ពន្ធខែមិថុនា ឆ្នាំ២០២០ តរៀងទៅ អ្នកជាប់ពន្ធទាំងឡាយត្រូវអនុវត្តស្របតាមសេចក្តីណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ការអនុវត្តវិធានការដូចបានជម្រាបជូនខាងលើ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ឧបសម្ព័ន្ធ៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

ទម្រង់បង់ប្រាក់ពន្ធ P101
ប្រកាសខែមករា ឆ្នាំ២០២១

# ពាក្យស្នើសុំបង់និងប្រកាសពន្ធប្រចាំខែ តាមប្រព័ន្ធអនឡាញ

| | |
|---|---|
| ឈ្មោះសហគ្រាស | ក្រុមហ៊ុន អេប៊ីស៊ី 14358 ខូអិលធីឌី |
| ជាអក្សរឡាតាំង | ABC 14358 Company Co.,Ltd |
| លេខអត្តសញ្ញាណកម្មសារពើពន្ធ | L001-100113753 |
| សកម្មភាពអាជីវកម្មចម្បង | មីក្រូហិរញ្ញវត្ថុ (ផ្តល់ប្រាក់កម្ចី) |
| អាសយដ្ឋាន | #១៨៩-១៩១E0 ផ្លូវកម្ពុជាក្រោម (១២៨) សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ |
| កាលបរិច្ឆេទបោះពុម្ព | 2021-02-20 13:44:59 |
| ទឹកប្រាក់ឥណទានយោងអតបពីខែមុន | 0 រៀល |
| ប្រាក់ពន្ធសរុបត្រូវបង់ | **3,267,000 រៀល** |

OEFI2021022000059

សូមបង្ហាញលេខកូដបារកូដ / QRកូដ ទៅធនាគារជាដៃគូដើម្បីបង់ប្រាក់

លោកអ្នកត្រូវបង់ប្រាក់ពន្ធអោយគ្រប់ចំនួន និងត្រឹមត្រូវនៅត្រឹម ថ្ងៃទី**25-02-2021** បើពុំនោះទេលោកអ្នកនឹងត្រូវបង់ពន្ធបន្ថែម និងការប្រាក់តាមច្បាប់ស្តីពីសារពើពន្ធ។

| ល.រ<br>No | ប្រភេទពន្ធដែលត្រូវប្រកាស<br>Type of Tax to be Filed Return | ឥណទានយោងពីខែមុន<br>Credit Last Month | ប្រាក់ពន្ធត្រូវបង់<br>Tax amount to be paid | ឥណទានយោងខែបន្ទាប់<br>Credit Next Month |
|---|---|---|---|---|
| 1 | 0006-ពន្ធលើប្រាក់បៀវត្ស<br>0006-Salary Tax | 0 ៛ | 2,725,000 ៛ | 0 ៛ |
| 2 | 0007-ពន្ធលើអត្ថប្រយោជន៍បន្ថែម<br>0007-Fringe Benefit Tax | 0 ៛ | 400,000 ៛ | 0 ៛ |
| 3 | 0008-ប្រាក់រំដោះពន្ធលើប្រាក់ចំណូល<br>0008-Prepayment of Profit Tax | 0 ៛ | 130,000 ៛ | 0 ៛ |
| 4 | 0012-ពន្ធកាត់ទុកលើសេវាកម្ម ១៥%<br>0012-Withholding Tax on Services 15% | 0 ៛ | 12,000 ៛ | 0 ៛ |
| 5 | 0023-អាករលើតម្លៃបន្ថែម<br>0023-Value Added Tax | 0 ៛ | 0 ៛ | 10,000,000 ៛ |
| 6 | 0024-អាករពិសេសលើទំនិញមួយចំនួន<br>0024-Specific Tax on Certain Merchandises | 0 ៛ | 0 ៛ | 0 ៛ |
| 7 | 0028-អាករសម្រាប់បំភ្លឺសាធារណៈ<br>0028-Public Lighting Tax | 0 ៛ | 0 ៛ | 0 ៛ |
| 8 | 0030-អាករលើការស្នាក់នៅ<br>0030-Accomodation Tax | 0 ៛ | 0 ៛ | 0 ៛ |
| | សរុបប្រាក់ពន្ធ<br>Total Amount | **0 ៛** | **3,267,000 ៛** | **10,000,000 ៛** |

ធ្វើនៅ.......................... ថ្ងៃទី......... ខែ............... ឆ្នាំ២០.......

**ម្ចាស់សហគ្រាសឬតំណាងស្របច្បាប់**

ហត្ថលេខា ឈ្មោះ និងត្រា

*ប្រសិនបើជាភ្នាក់ងារសេវាកម្មពន្ធដារ សូមផ្តល់លេខសម្គាល់*

☐☐☐☐☐☐☐☐☐☐

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ..៧១.៧៥..........អពដ

L202104080182 | TD3777

ថ្ងៃអាទិត្យ ៧កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២១

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃការស្កេន និងបញ្ជូន ពាក្យស្នើសុំ លិខិតរដ្ឋបាល ឯកសារនានា ឬលិខិតប្រកាសពន្ធ មកអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ តាមរយៈប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Documents Submission System)

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្នុងគោលបំណងចូលរួមកាត់បន្ថយនិងទប់ស្កាត់ហានិភ័យនានា នៃការរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19) ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាការជួយសម្រួលដល់អ្នកជាប់ពន្ធទូទៅ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំរួចរាល់នូវយន្តការនៃការស្កេន និងបញ្ជូនពាក្យស្នើសុំ លិខិតរដ្ឋបាល ឯកសារនានា ឬលិខិតប្រកាសពន្ធ មកអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត-ខណ្ឌ តាមរយៈប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Documents Submission System)។

អ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ ឬសាធារណជនដែលមានបំណងដាក់ពាក្យស្នើសុំ លិខិតរដ្ឋបាល ឯកសារនានា ឬលិខិតប្រកាសពន្ធ មកអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ អាចធ្វើការបញ្ជូនឯកសារទាំងនោះ ដោយគ្រាន់តែស្កេន ហើយបញ្ចូល (Upload) ឯកសារដែលបានស្កេនមកកាន់អគ្គនាយកដ្ឋានពន្ធដារតែម្តង។ ដើម្បីបញ្ចូល (Upload) ឯកសារទាំងនោះ អ្នកជាប់ពន្ធត្រូវចូលប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service) ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម÷

### ១. ប្រភេទពាក្យស្នើសុំ លិខិតរដ្ឋបាល ឯកសារនានា និងលិខិតប្រកាសពន្ធ

តាមរយៈប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Documents Submission System) អ្នកជាប់ពន្ធអាចដាក់ពាក្យស្នើសុំ លិខិតរដ្ឋបាល ឯកសារនានា និងលិខិតប្រកាសពន្ធ ជាអាទិ៍÷

- លិខិតប្រកាសពន្ធប្រចាំខែ ឬប្រចាំឆ្នាំ
- ពាក្យស្នើសុំបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ
- ពាក្យស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសឬអចលនទ្រព្យ
- ពាក្យស្នើសុំតវ៉ាលើការកំណត់ពន្ធឡើងវិញ
- ពាក្យស្នើសុំទូទាត់ប្រាក់ពន្ធជាដំណាក់កាល
- ពាក្យស្នើសុំវិញ្ញាបនបត្រ អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនានា
- ពាក្យស្នើសុំ លិខិតរដ្ឋបាល និងឯកសារនានា ។ល។



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

L202104080182 | TD3777

## ២. ការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service) អ្នកប្រើប្រាស់ដែលពុំទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធនេះ ដោយចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh/km/e-service ដើម្បីចុះឈ្មោះប្រើប្រាស់ ដោយត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម ÷

- អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ប្រព័ន្ធ
- លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង និង
- សារអេឡិចត្រូនិក (E-mail) សម្រាប់ទំនាក់ទំនង។

អ្នកប្រើប្រាស់នឹងទទួលបានសារអេឡិចត្រូនិក (E-mail) ដើម្បីដំណើរការគណនី ដោយតម្រូវឱ្យបញ្ចូលលេខសម្ងាត់នៅពេលព័ត៌មានតម្រូវខាងលើត្រូវបានវាយបញ្ចូលពេញលេញ។

## ៣. នីតិវិធីលម្អិតក្នុងការស្កេន និងបញ្ជូន

### ៣.១ ការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ

ក្នុងការដាក់លិខិតប្រកាសនិងទូទាត់ប្រាក់ពន្ធ លោក-លោកស្រីអាចបំពេញនិងដាក់លិខិតប្រកាសជា ២ ជម្រើសដូចខាងក្រោម÷

ក. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំត្រូវប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធ (E-Filing)។ សម្រាប់អ្នកជាប់ពន្ធតូចត្រូវប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)។ ចំពោះការទូទាត់ប្រាក់ពន្ធត្រូវអនុវត្តតាមប្រព័ន្ធទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment)។ ក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីខាងលើ អ្នកជាប់ពន្ធត្រូវអនុវត្តនីតិវិធីលម្អិតដូចខ្លឹមសារនៃសេចក្តីណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធទី ១ ដោយមិនចាំបាច់ស្កេននិងបញ្ជូនឯកសារមកអគ្គនាយកដ្ឋានពន្ធដារទៀតឡើយ។

ខ. បំពេញលិខិតប្រកាសពន្ធប្រចាំខែដោយដៃ និងបង់ប្រាក់ពន្ធដោយប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment) រួចស្កេនបញ្ជូនលិខិតប្រកាសនិងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធតាមរយៈប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Documents Submission System) ដោយអនុវត្តនីតិវិធីលម្អិតដូចខ្លឹមសារនៃសេចក្តីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធទី ២។

**សម្រាប់សហគ្រាសដែលស្ថិតក្នុងប្រភេទអាជីវកម្ម ដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ក្នុងអំឡុងពេលវិបត្តិនៃជំងឺកូវីដ-១៩ (COVID-19)** ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

- ជាបឋមត្រូវអនុវត្តនីតិវិធីដូចមានកំណត់ក្នុងចំណុច ក ឬចំណុច ខ ខាងលើ
- បន្ទាប់មក ត្រូវជ្រើសរើសប្រភេទ "ប្រកាសជាបន្ទុករដ្ឋ" ក្នុងប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Documents Submission System) និងត្រូវបញ្ចូល បារកូដ E-Filing ឬបារកូដ EVAT រួចបញ្ចូល (Upload) លិខិតប្រកាសពន្ធ ដោយភ្ជាប់មកជាមួយនូវ ពាក្យស្នើសុំបង់ប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣ ឬឯកសារគាំទ្រផ្សេងៗ។

L202104080182 | TD3777

### ៣.២ ការដាក់ពាក្យស្នើសុំ លិខិតរដ្ឋបាល ឬឯកសារនានា

ក្នុងការដាក់ពាក្យស្នើសុំ លិខិតរដ្ឋបាល ឬឯកសារនានា លោក-លោកស្រីអាចស្កេននិងបញ្ជូនពាក្យស្នើសុំ លិខិតរដ្ឋបាល ឬឯកសារនានា ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម÷

**ជំហានទី១÷** ចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh/km/e-service ដោយប្រើប្រាស់គណនីដែលបានបង្កើតរួច និងជ្រើសរើសយកប្រព័ន្ធ "**បញ្ជូនឯកសារអេឡិចត្រូនិក (E-Documents Submission System)**"

**ជំហានទី២÷** លោក-លោកស្រីអាចធ្វើការជ្រើសរើសយកប៊ូតុង "**ការបញ្ជូនឯកសារ ឬលិខិតទូទៅនានា**"

**ជំហានទី៣÷** ជ្រើសរើសប្រភេទបុគ្គលជា "**នីតិបុគ្គល**" ឬ "***រូបវន្តបុគ្គល***"

- ករណីជា "**នីតិបុគ្គល**" ត្រូវជ្រើសរើសប្រភេទអ្នកជាប់ពន្ធ រួចបញ្ចូលលេខអត្តសញ្ញាណកម្មសារពើពន្ធ
- ករណីជា "***រូបវន្តបុគ្គល***" ប្រព័ន្ធនឹងបង្ហាញឈ្មោះ លេខទូរស័ព្ទទំនាក់ទំនង និងសារអេឡិចត្រូនិកតែម្តង

**ជំហានទី៤÷** បន្ទាប់មកត្រូវជ្រើសរើសអង្គភាពពន្ធដារដែលលោក-លោកស្រីត្រូវបញ្ជូនលិខិត ឧទាហរណ៍÷ ***នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ, សាខាពន្ធដារខណ្ឌចំការមន ។ល។***

**ជំហានទី៥÷** ស្កេនលិខិត ឬឯកសារពាក់ព័ន្ធ ដែលត្រូវដាក់បញ្ជូនមក

**ជំហានទី៦÷** រួចដាក់បញ្ចូល (Upload) ទៅក្នុងប្រព័ន្ធ និងចុចប៊ូតុង "**បញ្ជូន**" ជាការស្រេច

**ជំហានទី៧÷** លោក-លោកស្រីនឹងទទួលបានសារអេឡិចត្រូនិក ដែលបញ្ជាក់ថា "បានទទួល" អមដោយលិខិតបញ្ជាក់ការទទួលឯកសារ ឬសារបញ្ជាក់ថាបដិសេធឯកសារមិនទទួល បន្ទាប់ពីពេលបញ្ជូនឯកសាររួចរាល់។

*ដើម្បីធ្វើការស្វែងយល់បន្ថែមអំពីនីតិវិធីខាងលើ អ្នកប្រើប្រាស់អាចទូរស័ព្ទមក GDT Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android ឬតាមរយៈ Telegram Channel* ***ព័ត៌មានពន្ធដារកម្ពុជា*** *(https://t.me/gdtcambodianews)*

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ការអនុវត្តវិធានការដូចបានជម្រាបជូនខាងលើ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**ចម្លងជូន÷**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ.
  "ដើម្បីគោរពជូនជ្រាប"
- ឯកឧត្តម-លោកជំទាវ អគ្គនាយករង
- អង្គភាពក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ